# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូត នៅព្រះសហាគមន៍សន្តីម៉ារីញញឹម
# ចំការទៀង ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០
# ព្រះបន្ទូលចាប់កំណើតជាមនុស្ស

**អត្ថបទទី១៖ អេសាយ ៩,១-៦**

ប្រជាជនដែលដើរក្នុងភាពងងឹត បានឃើញពន្លឺមួយដ៏ចិញ្ចែងចិញ្ចាច។ អស ៩,១

**អត្ថបទទី២៖ ទីតុស ២,១១-១៤**

ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រណីសន្តោសមក ដើម្បីសង្គ្រោះមនុស្សទាំងអស់។ ទត ២,១១

**ដំណឹងល្អ៖ លូកា ២,១-១៤**

កុំខ្លាចអ្វីឡើយ ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នា។ លក ២,១០

បងប្អូនជាទីស្រឡាញ់!

ព្រះអម្ចាស់យេស៊ូប្រសូតហើយ ខ្ញុំសូមស្វាគមន៍បងប្អូនដែលចូលរួមដោយផ្ទាល់ និងបងប្អូនដែលចូលរួមតាមហ្វេសបុក យូធូប ក្នុងអភិបូជាអបអរសាទរបុណ្យព្រះយេស៊ូប្រសូតឆ្នាំ ២០២០នេះ។ យើងដឹងថាឆ្នាំនេះ យើងមានព្រំដែនយ៉ាងច្រើនដើម្បីជួបជុំគ្នា ហេតុនេះហើយទោះបីខ្ញុំនៅឆ្ងាយពីបងប្អូន ប៉ុន្តែយើងដឹងថានៅក្នុងការអធិដ្ឋាន និងតាមរយៈមធ្យោបាយទំនើបៗដែលយើងមានសព្វថ្ងៃ យើងជិតស្និទ្ធរួមជាមួយគ្នាដើម្បីគោរពព្រះយេស៊ូដែលជាអម្ចាស់ ព្រះយេស៊ូដែលជាពន្លឺនៅក្នុងភាពងងឹតនៃជីវិតរបស់យើង។ នៅក្នុងភូមិភាគភ្នំពេញយើងមាន៥០កន្លែង តាមកន្លែងនីមួយៗយប់នេះយើងមានគ្នាប្រហែលដប់នាក់ឬម្ភៃនាក់ដែលអាចជួបជុំគ្នាបាន។ ប៉ុន្តែ តាមមធ្យោបាយព័ត៌មានថ្មីៗប្រហែលយើងមានរាប់ពាន់នាក់ ដើម្បីចែករំលែកអំណរសប្បាយដែលយើងមាននៅក្នុងភាពងងឹតនៃជីវិតរបស់យើង។ យើងមើលឃើញព្រះសង្គ្រោះ ពិតមែនយប់នេះយើងជួបជុំគ្នា ដើម្បីសំឡឹងមើលអាថ៌កំបាំងនៃជីវិត ដើម្បីសំឡឹងមើលការអស្ចារ្យនៃជីវិត។

យប់នេះ យើងនឹករលឹកដល់២០០០ឆ្នាំមុន នៅក្នុងភូមិបេថ្លេហិមដែលជាភូមិដ៏តូចមួយមានកូនង៉ែតមួយដែលបានប្រសូតហើយ មានកូនង៉ែតមួយដែលបានទទួលជីវិតហើយ។ យប់នេះ រួមជាមួយព្រះនាងម៉ារីដែលពោរពេញដោយអំណរសប្បាយ រួមជាមួយលោកយ៉ូសែបដែលកំពុងសំឡឹងមើលកូនរបស់គាត់ រួមជាមួយគ្រូគង្វាល ហោរាចារ្យ មហាជន ទេវទូត យើងទាំងអស់គ្នាពោរពេញដោយអំណរសប្បាយ។ យើងមកដើម្បីសំឡឹងមើលជីវិតថ្មី យើងដឹងថាពេលគ្រួសារមួយបានទទួលជីវិតថ្មីម្នាក់គេពោរពេញដោយអំណរសប្បាយ។ ប៉ុន្តែ ជីវិតដែលយើងស្វាគមន៍ថ្ងៃ

នេះ ជីវិតដែលយើងទទួលនៅក្នុងអំណរសប្បាយយប់នេះ មានឈ្មោះមួយយ៉ាងពិសេស 〝**បុត្រនោះទទួលអំណាចគ្រប់គ្រង និងគេថ្វាយព្រះនាមថា ព្រះដ៏គួរស្ញើចសរសើរប្រកបដោយព្រះប្រាជ្ញាញាណ ព្រះដ៏មានតេជានុភាពសព្វប្រការនិងអំណាច ព្រះបិតាដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអម្ចាស់នៃសន្តិភាព**〞។ នេះជាព្រះនាមរបស់កូនង៉ែតដែលយើងទទួលស្វាគមន៍នារាត្រីនេះ យប់នេះទេវទូតបានច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ 〝**សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត**〞។ ដោយសារ យប់នេះនៅភូមិបេថ្លេហិមមានកូនង៉ែតម្នាក់ដែលកើតមក គឺព្រះគ្រីស្តជាអម្ចាស់ដែលជាព្រះសង្គ្រោះដ៏ពិតប្រាកដមែន។

ព្រះយេស៊ូបានប្រសូតនៅក្នុងភាពសម្ងាត់ក្នុងក្រោលគោ ឆ្ងាយពីផ្ទះរបស់ឪពុកម្តាយ ឆ្ងាយពីភូមិកំណើតផ្ទាល់ខ្លួន ឆ្ងាយពីគ្រួសារ ពីបងប្អូន ពីអ្នកជិតខាង ពីប្រាំបួនខែកន្លងមកមានអំណរសប្បាយរួមជាមួយព្រះនាងម៉ារី ដើម្បីទន្ទឹងរង់ចាំកូននេះ។ ប៉ុន្តែ កូនង៉ែតនេះបានកើតនៅភូមិបេថ្លេហិម ដោយសារថ្ងៃនោះគេធ្វើជំរឿនប្រជាជន ហេតុនេះហើយព្រះនាងម៉ារីនិងលោកយ៉ូសែបត្រូវការចេញពីភូមិកំណើតដើម្បីចេញទៅកន្លែងមួយទៀត។ ដូច្នេះ ព្រះយេស៊ូបានប្រសូតនៅក្នុងភាពស្ងៀមស្ងាត់ ឆ្ងាយពីបងប្អូន ឆ្ងាយពីគ្រួសារ ឆ្ងាយពីមិត្តភក្តិ។

ព្រះយេស៊ូបានប្រសូតនៅក្នុងភាពភ័យខ្លាចដែរ ដោយសារនៅពេលស្តេចហេរ៉ូដបានទទួលដំណឹងថា 〝**មានស្តេចមួយអង្គដែលប្រសូតហើយ ជាព្រះសង្គ្រោះ**〞 ភ្លាមនោះស្តេចហេរ៉ូដបានសម្រេចចិត្តសម្លាប់កូនង៉ែតទាំងអស់។ ជាមូលហេតុ នៅពេលព្រះយេស៊ូប្រសូតភ្លាមៗ លោកយ៉ូសែបបាននាំព្រះនាងម៉ារីនិងកូន ចេញធ្វើដំណើរគេចពីប្រទេសផ្ទាល់ខ្លួន ចូលនៅក្នុងប្រទេសអេហ្ស៊ីបដោយសារគេភ័យខ្លាច។

ប្រសិនបើយើងមើល កូនង៉ែតដ៏អស្ចារ្យនេះបានកើតនៅក្នុងពិភពមួយដែលស្ងៀមស្ងាត់ និងនៅក្នុងភាពភ័យខ្លាច។ ប៉ុន្តែ កូននេះជាព្រះអម្ចាស់នៃសុខសន្តិភាព កូននេះដែលកំពុងបើកភ្នែក ដើម្បីមើលឃើញពិភពថ្មីដែលកើតឡើងនៅមុខគាត់ គាត់បានឃើញភូមិដ៏តូចមួយក្នុងស្រុកយូដា ដែលមានសត្វមួយចំនួន មានឪពុកម្តាយ មានគ្រូគង្វាល មានហោរាចារ្យ ដែលបានមកថ្វាយបង្គំនិងស្វាគមន៍។

នៅក្នុងឆ្នាំ២០២០នេះ ប្រហែលយើងមានអារម្មណ៍ដូចគ្នាដែរ យើងរួមរស់នៅក្នុងភាពស្ងៀមស្ងាត់ នៅក្នុងការភ័យខ្លាច។ សព្វថ្ងៃ នៅកន្លែងនីមួយៗបីដូចជាមានសេចក្តីស្លាប់កំពុងធ្វើដំណើរ មានមេរោគថ្មីៗដែលកំពុងរាលដាលពីប្រទេសមួយទៅប្រទេសមួយ។ ខ្ញុំបាននឹកឃើញនៅថ្ងៃដែលព្រះយេស៊ូសោយទិវង្គត និងថ្ងៃដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញខ្ញុំបាននៅចំ

ការទៀងនេះម្នាក់ឯង ដោយសង្ឃឹមថាប៉ុន្មានខែទៀតយើងពោរពេញដោយអំណរសប្បាយ ដោយសាររឿងកូវីដ-១៩ទៅជារឿងចាស់ដែលយើងអាចភ្លេច។ ប៉ុន្តែ យប់ដែលព្រះយេស៊ូប្រសូត ខ្ញុំបាននៅទីនេះម្នាក់ឯងម្តងទៀត ដើម្បីថ្វាយពិធីបុណ្យដ៏សំខាន់បំផុតសម្រាប់ជីវិតរបស់យើង។ រាល់ឆ្នាំណែនាំឲ្យមានបងប្អូនរាប់ពាន់នាក់មកជួបជុំគ្នា ទាំងកូនក្មេង ទាំងចាស់ ទាំងយុវជនយុវនារី នៅក្នុងអំណរសប្បាយ។ ប៉ុន្តែឆ្នាំនេះថ្ងៃនេះ យើងដឹងថាព្រំដែន ការបិទពិធីអាពាហ៍ពិពាហ៍ ការបិទការជួបជុំគ្នា តែនៅក្នុងអំណរសប្បាយនិងសេចក្ដីសង្ឃឹមរបស់យើង យប់នេះយើងនៅសល់គ្នាតិច។ ដូចនៅថ្ងៃដែលព្រះយេស៊ូប្រសូតក្នុងភូមិបេថ្លេហិមដែរ មានតែព្រះនាងម៉ារី លោកយ៉ូសែប គ្រូគង្វាល ហោរាចារ្យ សត្វមួយចំនួនដែលនៅជាមួយព្រះយេស៊ូ។

ទោះបីយើងមានព្រំដែនយ៉ាងច្រើននៅក្នុងការជួបជុំគ្នា ទោះបីយើងត្រូវការបិទកម្មវិធីនានាដែលយើងបានត្រៀមខ្លួនពីយូរខែហើយ ទោះបីយើងមិនអាចរៀបចំពិធីជប់លៀងដូចយើងបានធ្វើជារៀងរាល់ឆ្នាំ យើងដឹងថាព្រះយេស៊ូប្រសូតហើយ។ គ្មានព្រឹត្តិការណ៍ណាមួយ ដែលរារាំងមិនឲ្យព្រះយេស៊ូប្រសូតបាននោះទេ ទោះបីនៅសម័យព្រះយេស៊ូប្រសូតគ្មានកន្លែងតាមផ្ទះសំណាក់ គ្មានមណ្ឌលសុខភាពដើម្បីស្វាគមន៍នាងម៉ារី។ នៅពេលនោះ មានតែភាពច្រណែនរបស់ស្ដេចហេរ៉ូដដែលចង់សម្លាប់ព្រះឱរស្តយេស៊ូ តែគ្មានព្រឹត្តិការណ៍ណាមួយដែលណែនាំឲ្យព្រះយេស៊ូប្រសូតមិនបាននោះទេ។

ដូច្នេះ ថ្ងៃនេះយប់នេះយើងដឹងថាជីវិតថ្មីបានប្រសូតហើយ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្សនៅទីនេះឥលូវនេះ។ ពិតមែន យើងសោកស្ដាយណាស់ដែលយើងមិនអាចជួបជុំគ្នាដូចរាល់ឆ្នាំ ប៉ុន្តែយប់នេះអស់ពីដួងចិត្តខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់។ ដោយសារយប់នេះ យើងទទួលស្វាគមន៍ព្រះអំណោយទានមួយយ៉ាងពិសេសបំផុត គឺជីវិតព្រះយេស៊ូគ្រីស្តដែលជាព្រះបន្ទូលចាប់កំណើតជាមនុស្ស គឺព្រះជាម្ចាស់ផ្ទាល់ដែលចូលនៅក្នុងប្រវត្តិសាស្ត្ររបស់យើង ដើម្បីធ្វើដំណើរជាមួយយើង។ ឆ្នាំនេះ យើងបានជួបជុំគ្នាតិច យើងបានរៀបចំកម្មវិធីខ្លះៗជាមួយកូនក្មេងតាមព្រះសហគមន៍ យើងបានយកចិត្តទុកដាក់តុបតែងបរិវេណព្រះសហគមន៍ យើងបានរៀបចំដើម្បីទទួលស្វាគមន៍ព្រះយេស៊ូ។ យើងបានយកចិត្តទុកដាក់រៀបចំដួងចិត្តរបស់យើង ដើម្បីឲ្យដួងចិត្តរបស់យើងទៅជាព្រះដំណាក់យ៉ាងពិសេស។ ដូច្នេះ យប់នេះរួមជាមួយលោកឪពុកទាំងអស់ក្នុងភូមិភាគភ្នំពេញ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ភាពស្មោះត្រង់ ចិត្តអត់ធ្មត់ និងការយកចិត្តទុកដាក់របស់លោកឪពុកតាមកន្លែងនីមួយៗ។ យប់នេះរួមជាមួយបងប្រុសបងស្រីទាំងអស់ក្នុងភូមិភាគភ្នំពេញ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ជំនឿ ការយកចិត្តទុកដាក់ ជាពិសេសយកចិត្តទុកដាក់លើសេចក្ដីត្រូវ

ការរបស់បងប្អូនតូចតាច ដើម្បីឲ្យជីវិតរបស់ព្រះយេស៊ូទៅគ្រប់ទីកន្លែង។ ជាពិសេសយប់នេះ រួមជាមួយបងប្អូនដែលជាគ្រីស្តបរិស័ទ រួមជាមួយយុវជនយុវនារី រួមជាមួយមេកាយរឹទ្ធិ រួមជាមួយកូនកាយរឹទ្ធិ រួមជាមួយបងប្អូនដែលកំពុងស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់ រួមជាមួយក្រុមសិល្បៈទាំងអស់នៅក្នុងព្រះសហាគមន៍របស់យើង។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ និងលើកតម្កើងព្រះជាម្ចាស់សម្រាប់សេចក្តីស្រឡាញ់របស់បងប្អូន សម្រាប់សេចក្តីសង្ឃឹមដែលបងប្អូនបានបង្ហាញយ៉ាងជាក់ស្តែង ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងជីវិត និងដើម្បីចែករំលែកព្រះយេស៊ូជាមួយបងប្អូនឯទៀតៗ។

យប់នេះព្រះយេស៊ូប្រសូតហើយ នេះជាដំណឹងល្អដែលយើងចង់ចែករំលែកជាមួយបងប្អូនយ៉ាងច្រើន។ ស្ថានភាពនៃជំងឺកូវីដ-១៩ បានណែនាំឲ្យយើងមើលឃើញយ៉ាងជាក់ស្តែងអំពីភាពខ្សោយនៃជីវិតរបស់យើង អំពីភាពខ្សោយនៃពិភពលោករបស់យើង។ ប៉ុន្តែ យើងបានយល់ថាដោយសារជំងឺកូវីដ-១៩ យើងមានសេចក្តីត្រូវការមួយដ៏សំខាន់បំផុត គឺបងប្អូនដែលស្រឡាញ់យើង ឲ្យយើងមានភាតរភាពរវាងគ្នានឹងគ្នា ឲ្យយើងមានសាមគ្គីភាពរវាងគ្នានឹងគ្នា ដើម្បីកសាងជីវិតរបស់យើងផ្ទាល់ឲ្យទៅមុខ ដើម្បីកសាងជីវិតនៃពិភពលោករបស់យើងឲ្យទៅមុខដែរ។ ពិតមែនសព្វថ្ងៃ យើងរស់នៅក្នុងស្ថានភាពដែលណែនាំឲ្យយើងចេះតែសង្ស័យ ណែនាំឲ្យយើងចេះតែគិតថាធ្វើដូចម្តេចដើម្បីឲ្យថ្ងៃស្អែក យើងអាចបំពេញគម្រោងការរបស់យើងបាន។ ថ្ងៃនេះ យើងមានប៉ុន្មានគ្រួសារដែលកំពុងឈឺចិត្ត ដោយសារតែមិនអាចរៀបចំមង្គលការឲ្យកូនប្រុសស្រីរបស់គេបាន។ យើងដឹងថាសិស្សានុសិស្សរបស់យើងក៏ឈឺចិត្តដែរ ដោយសង្ឃឹមថាបានចូលរៀនពីខែតុលាក្រោយមកលើកដល់ខែធ្នូ ឥលូវលើកដល់ចុងខែមករាឆ្នាំក្រោយ។ ដូច្នេះ យើងមានការសង្ស័យច្រើន មានព្រឹត្តិការណ៍យ៉ាងច្រើនដែលណែនាំឲ្យគម្រោងការរបស់យើងប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ឲ្យទំលាប់របស់យើងត្រូវតែកែប្រែពីមួយថ្ងៃទៅមួយថ្ងៃ។

ប៉ុន្តែ វិបត្តិដែលយើងជួបសព្វថ្ងៃនៅក្នុងជីវិត នៅក្នុងសង្គម នៅក្នុងពិភពលោក ជាវិបត្តិដែលជួយយើងដើម្បីឲ្យយើងរីកចម្រើន ដើម្បីឲ្យយើងទទួលកម្លាំងសាជាថ្មី ដើម្បីឲ្យយើងចាក់គ្រឹះនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏ពិតប្រាកដមែន។ ដោយសារយើងដឹងថា ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់បាននៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ដូច្នេះ ជីវិតរបស់យើងកុំឲ្យយើងទីពឹងលើអនាគត ប៉ុន្តែឲ្យយើងយកចិត្តទុកដាក់ទីពឹងលើបច្ចុប្បន្ននេះ។ ទីពឹងពីមួយថ្ងៃទៅមួយថ្ងៃដោយទុកចិត្តលើព្រះជាម្ចាស់ ដោយមានសេចក្តីក្លាហាន ដោយមានការតស៊ូ ដោយមានភក្តីភាពដោយដឹងថាពិតមែនព្រះជាម្ចាស់គង់នៅជាមួយយើង។ ដោយសារយប់នេះ យើងមើលឃើញយ៉ាងជាក់ស្តែងព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់។ ជាហេតុដែលព្រះជាម្ចាស់បាន

ប្រទានព្រះបុត្រាតែមួយព្រះអង្គគត់ យាងមកនៅក្នុងពិភពលោកនេះដើម្បីសង្គ្រោះយើង។ ហេតុនេះហើយ សេចក្ដីសង្ឃឹមរបស់យើងចេញជារូបរាងនៅថ្ងៃនេះ នៅរាត្រីដែលព្រះយេស៊ូប្រសូត។ នៅក្នុងដៃរបស់យើង នៅក្នុងដួងចិត្តរបស់យើង យើងទទួលស្វាគមន៍សេចក្ដីសង្ឃឹមនេះសម្រាប់ពិភពលោក សម្រាប់ប្រទេសកម្ពុជា សម្រាប់ភូមិភាគភ្នំពេញ នៅថ្ងៃនេះ នៅពេលនេះ ឥលូវនេះ។

សូមព្រះជាម្ចាស់ ប្រទានព្រះពរដល់បងប្អូនទាំងអស់ សូមព្រះជាម្ចាស់ថែរក្សាការពារទាំងសុខភាព ទាំងសុវត្ថិភាពរបស់បងប្អូនទាំងអស់ ដើម្បីឲ្យយើងរួមរស់នៅក្នុងឆ្នាំ២០២១ក្នុងសេចក្ដីសង្ឃឹមដែលយើងទទួលយប់នេះ។ ព្រះជាម្ចាស់គង់នៅជាមួយយើង អេម៉ាណូអែលបានប្រសូតហើយ ព្រះជាម្ចាស់គង់នៅជាមួយយើង។ អាម៉ែន៕